## បំផុសគំនិត

### សកម្មភាពច្នៃប្រឌិត

ក្នុងសៀវភៅមគ្គុទេសក៍នេះ ប្អូនបានយល់ដឹងច្រើនពីអតីតកាលរបស់ប្រទេសកម្ពុជា និងពីរបៀបយើងប្រឈមមុខនឹងរឿងនោះ។ ឥឡូវនេះ សូមចំណាយពេលបន្តិច ត្រលប់ទៅអ្វីដែលប្អូនបានអាន ហើយសូមគូររូប **ប្រទេសកម្ពុជាក្នុងសន្តិភាព** នាពេលបច្ចុប្បន្ន។ មិនបាច់ទាល់តែចេះគូរក៏បាន! ទុកឱ្យរូបនិមិត្តសញ្ញាខាងក្រោមបំផុសគំនិតប្អូនវិញ។




### រកមើលរូប

រូបសញ្ញាសន្តិភាព និងយុត្តិធម៌លាក់នៅក្របខាងមុខ។ តើប្អូនអាចរករូបទាំងនោះឃើញទេ?

### ចម្លើយ

១ → គាត់មានអាយុ ១០ឆ្នាំ

២ → គេបញ្ជូនគាត់ទៅធ្វើការទាំងបង្ខំនៅការដ្ឋាន

៣ → ដើម្បីប្រាប់រឿងរ៉ាវគាត់ និងស្វែងរកយុត្តិធម៌

៤ → មេដឹកនាំខ្មែរក្រហម ១០រូប ត្រូវបានស៊ើបអង្កេត

៥ → «លោកស្រីចៅក្រមជាទីគោរព»

៦ → ដើមបណ្ដឹងរដ្ឋប្បវេណី

៧ → ក្ងួរផ្លែអូលីវ

៨ → គម្រោងសំណងចំនួន ២៦

៩ → ដើម្បីទាមទារយុត្តិធម៌ និងការបិទបញ្ចប់សំណុំរឿង និងធ្វើឱ្យរបួសផ្លូវចិត្តធូរស្បើយ

## ស្វែងយល់បន្ថែម


**មជ្ឈមណ្ឌលធនធាន អ.វ.ត.ក.**
អគារលេខ៤០
មហាវិថីសហព័ន្ធរុស្ស៊ី
(ផ្លូវលេខ១១០) រាជធានីភ្នំពេញ

**មានសំណួរ?**
**សូមទាក់ទងមកកាន់យើងខ្ញុំ!**
ទូរស័ព្ទ៖ (+៨៥៥) ០២៣ ៨៦១ ៥២៥
អ៊ីម៉ែល៖ resource.centre@eccc.gov.kh




9 789924 974765 >

**បណ្ណសារ៖** កន្លែងរក្សាទុកឯកសារប្រកបដោយសុវត្ថិភាព ដើម្បីអ្នកស្រាវជ្រាវអាចចូលប្រើប្រាស់បាននាពេលបច្ចុប្បន្ន និងអនាគត។

**យុត្តិសាស្ត្រ៖** ការសិក្សាច្បាប់ និងរបៀបដែលច្បាប់ត្រូវបានអនុវត្ត នៅក្នុងសង្គម ដើម្បីនាំមកនូវយុត្តិធម៌ជូនប្រជាជន។

# សៀវភៅមគ្គុទេសក៍សម្រាប់កុមារ អំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ស្វែងយល់ពីការជំនុំជម្រះក្ដីខ្មែរក្រហម




### សិក្សាពីអតីតកាលកម្ពុជាតាមរយៈវិធីសាស្ត្រងាយៗ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) គឺជាសាលាជម្រះក្ដីដែលបានចាប់ដំណើរការនៅឆ្នាំ២០០៦ បង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលកើតឡើង នៅចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩។

**សំណួរខាងក្នុង**
ចង់ដឹង ថាប្អូនរៀនបានអ្វីខ្លះ ពីមួយទំព័រទៅមួយទំព័រ!


អំពីប្រវត្តិសាស្ត្រ ទំ.២
ការស្វែងរកយុត្តិធម៌ ទំ.៤
កេរដំណែលនៃយុត្តិធម៌ ទំ.៦
សម្រាប់មនុស្សជំនាន់ក្រោយ ទំ.៧
បំផុសគំនិត ទំ.៨

អំពីប្រវត្តិសាស្ត្រ

# សក្ខីកម្មលោកយាយខ្ញុំ







**ការជម្លៀសប្រជាជន៖** ខ្មែរក្រហមបានបង្ខំឱ្យប្រជាជនចាកចេញពីលំនៅដ្ឋាន ហើយចាត់ឱ្យទៅរស់នៅ និងធ្វើការនៅទីជនបទ។

**ការដ្ឋាន/សហករណ៍៖** ទីតាំងនានាដែលខ្មែរក្រហមបញ្ជូនប្រជាជនទៅធ្វើការទាំងបង្ខំ។






ផ្អែកលើរឿងរ៉ាវនៃដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានផ្ដល់សក្ខីកម្ម នៅចំពោះមុខ អ.វ.ត.ក។

## តើខ្មែរក្រហមជានរណា?

ខ្មែរក្រហម និងមេដឹកនាំរបស់ពួកគេ ព្យាយាមប្រែក្លាយកម្ពុជាទៅជាប្រទេសមួយដែលមានតែវណ្ណៈកម្មករ និងកសិករ ប៉ុន្តែអំពើរបស់ពួកគេបំផ្លាញប្រទេស ហើយបានបង្កភាពឈឺចាប់ដល់ប្រជាជនគ្រប់រូប។

- សម័យកាល៖ ១៧ មេសា ១៩៧៥ ដល់ ៧ មករា ១៩៧៩
- ការបង្ខំឱ្យធ្វើការ ការធ្វើបាប ការបង្អត់អាហារ
- សមាជិកគ្រួសារបាត់ខ្លួន ឬ បាត់បង់ជីវិត



### កម្មាភិបាលខ្មែរក្រហម

ខ្មែរក្រហមតម្រូវឱ្យប្រជាជនស្លៀកពាក់ពណ៌ខ្មៅ ឬពណ៌បៃតងចាស់ ដូចជាកសិករដូច្នេះដែរ។ ទាហានខ្មែរក្រហមជាច្រើនស្ពាយកាំភ្លើងជាប់ខ្លួន ដើម្បីបង្ហាញពីអំណាច និងការគ្រប់គ្រង។

### សំណួរ៖

១ ពេលរបបខ្មែរក្រហមចាប់ផ្ដើម តើសុវណ្ណនីដែលជាយាយរបស់សុធី មានអាយុប៉ុន្មាន?

..................................................

២ ក្រោយក្រុងភ្នំពេញដួលរលំ តើគេបញ្ជូនសុវណ្ណនីទៅធ្វើការនៅឯណា?

..................................................

..................................................

៣ ហេតុអ្វីសុវណ្ណនីសម្រេចចិត្តផ្ដល់សក្ខីកម្មនៅសាលាក្ដីខ្មែរក្រហម?

..................................................

..................................................

..................................................

**អំពើប្រល័យពូជសាសន៍៖** ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរកំណត់លើក្រុមមនុស្សព្រោះតែអត្តសញ្ញាណរបស់ពួកគេ ជាអំពើដែលខ្មែរក្រហមបានប្រព្រឹត្តក្នុងប្រទេសកម្ពុជា។

**ឧក្រិដ្ឋកម្មសង្គ្រាម/ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖** ជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលខ្មែរក្រហមបានប្រព្រឹត្តក្នុងប្រទេសកម្ពុជា។

ការស្វែងរកយុត្តិធម៌

# ស្វែងយល់អំពីការជំនុំជម្រះ



### តើការជំនុំជម្រះគឺជាអ្វី?

ពេលដែលតុលាការសម្រេចថាជនណាម្នាក់បានប្រព្រឹត្តបទឧក្រិដ្ឋ ផ្អែកតាមភ័ស្តុតាង និងច្បាប់។

### ដំណើរការកាត់ក្តីខ្មែរក្រហម

ការជំនុំជម្រះធ្វើឡើងក្នុងសាលសវនាការ អ.វ.ត.ក. ក្នុងទីក្រុងភ្នំពេញ។ សវនាការមានចំនួន **៦៣៩ថ្ងៃ**។ ការជំនុំជម្រះចុងក្រោយ បញ្ចប់នៅឆ្នាំ **២០២២** នៅពេលដែលមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចុងក្រោយ ដែលនៅមានជីវិត ត្រូវបានបញ្ជាក់ថាមានទោស។

### ខាងក្នុងសាលសវនាការ

**ព្រះរាជអាជ្ញា៖** ជាអ្នកច្បាប់ដែលយកសំណុំរឿងជនល្មើសខ្មែរក្រហមទៅកាន់តុលាការ។ ពួកគេតំណាងដល់ ប្រជាជនកម្ពុជាគ្រប់រូប។

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖** ជាមេធាវីដែលតំណាងផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។

**ចៅក្រម៖** ជាអ្នកកាត់សេចក្តី ដែលស្តាប់ព្រះរាជអាជ្ញា ចុងចោទ និងដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការហើយសម្រេចក្តីដោយផ្អែកលើភ័ស្តុតាង និង ច្បាប់។

**ជនជាប់ចោទ៖** ជាអ្នកដែលត្រូវជំនុំជម្រះ ចុងបញ្ចប់ការជំនុំជម្រះ ចៅក្រមនឹងសម្រេចថាជនជាប់ចោទ មានទោស ឬគ្មាន។

**មេធាវីការពារក្តី៖** ជាមេធាវីដែលការពារសិទ្ធិរបស់ជនសង្ស័យ និងជនជាប់ចោទ។



**ដើមបណ្តឹងរដ្ឋប្បវេណី៖** ជាជនរងគ្រោះផ្ទាល់ ឬប្រយោលពីរបបខ្មែរក្រហម ដែលចង់ផ្តល់ចម្លើយរបស់ខ្លួននៅក្នុងតុលាការ។ ពួកគេមានមេធាវីជាតំណាង។

មនុស្សជាង **២៨៤.000** នាក់ បានតាមដានការកាត់ទោសពីសាលសាធារណៈ នៅខាងក្រៅបន្ទប់សវនាការ។

| | |
|---|---|
| **៦** សំណុំរឿង | **៣.៩៤៥** ដើមបណ្តឹងរដ្ឋប្បវេណី |
| **៦** សាលក្រម/សាលដីកា | **១៦** ឆ្នាំនៃការកាត់ក្តី |

### តើជនរងគ្រោះបានចូលរួមដល់ការស្វែងរកយុត្តិធម៌ដោយរបៀបណា?

អ្នករស់រានពីឧក្រិដ្ឋកម្មខ្មែរក្រហមចែករំលែករឿងរ៉ាវរបស់ពួកគេ គឺជួយឱ្យចៅក្រម អ.វ.ត.ក. ប្រមូលព័ត៌មានសំខាន់ៗ ដើម្បីយល់ពីរឿងរ៉ាវដែលបានកើតឡើង និងថាតើអ្នកណាជាអ្នកទទួលខុសត្រូវ។

**ភ័ស្តុតាង៖** ព័ត៌មានដែលប្រមូលបាន ក្នុងអំឡុងពេលស៊ើបអង្កេតដែលជួយកំណត់ពីរឿងរ៉ាវដែលបានកើតឡើងក្នុងសំណុំរឿងមួយ និងអ្នកទទួលខុសត្រូវលើរឿងនោះ។

**សំណុំរឿង៖** ជាឈ្មោះអង្គហេតុនៅពេលដែលព្រះរាជអាជ្ញាចោទប្រកាន់នរណាម្នាក់ដែលបំពានច្បាប់។



# ការស៊ើបអង្កេត

### មនុស្ស១០រូបនាក់ ត្រូវស៊ើបអង្កេតដោយ អ.វ.ត.ក.






**តើប្អូនធ្លាប់ឮឈ្មោះ ប៉ុល ពត ឬ បងធំទី១ដែរឬទេ?** គាត់ជាមេដឹកនាំខ្មែរក្រហម។ ប៉ុន្តែ គាត់បានស្លាប់នៅឆ្នាំ ១៩៩៨ មុនពេលបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងមុនពេលការជំនុំជម្រះក្តីចាប់ផ្តើម។

### ហេតុអ្វីមិនមានការស៊ើបអង្កេតលើជនសង្ស័យទាំងអស់?

អ.វ.ត.ក. ផ្តោតលើតែមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មខ្មែរក្រហមដើម្បីសម្រេចបាននូវយុត្តិធម៌ សន្តិភាព និងការផ្សះផ្សានៅកម្ពុជា។

## ជួបជាមួយចៅក្រម



លោកស្រីចៅក្រមជាទីគោរព

### តើអ្នកមានតួនាទីអ្វីខ្លះអំឡុងពេលជំនុំជម្រះ?

ខ្ញុំពិនិត្យភ័ស្តុតាងទាំងអស់ ហើយស្តាប់សក្ខីកម្មរបស់ជនរងគ្រោះ។ ក្រោយមក ខ្ញុំធ្វើការសម្រេចចិត្តអំពីជនសង្ស័យ និងជនជាប់ចោទ ផ្អែកលើភ័ស្តុតាង និងច្បាប់។

### ហេតុអ្វីអង្គជំនុំជម្រះចំណាយពេលយូរម្ល៉េះដើម្បីបញ្ចប់?

យើងត្រូវស្វែងរកព័ត៌មានអំពីឧក្រិដ្ឋកម្មដែលបានកើតឡើងតាំងពីយូរហើយ ហើយត្រូវស្តាប់ជនរងគ្រោះច្រើននាក់។ យើងត្រូវកត់ត្រាហេតុផលសេចក្តីសម្រេចរបស់យើង - កំណត់ត្រាខ្ទង់ពាន់ទំព័រឯណោះ!

### តើអ្វីទៅជាលក្ខណៈពិសេសនៃអង្គជំនុំជម្រះនេះ?

ទំនៀមទម្លាប់កម្ពុជាលាយនឹងអន្តរជាតិ ក្នុងបែបវប្បធម៌ចម្រុះមួយ។ ខ្ញុំធ្វើការជាមួយចៅក្រម មេធាវី ទាំងខ្មែរ និងបរទេស។ ប្រទេសជាច្រើនគាំទ្រដំណើរការស្វែងរកយុត្តិធម៌របស់យើង។

**សំណួរ៖**

④ តើខ្មែរក្រហមប៉ុន្មាននាក់ត្រូវបានស៊ើបអង្កេត?

........................................................

........................................................

⑤ តើប្អូននិយាយយ៉ាងដូចម្តេចទៅកាន់ចៅក្រម?

........................................................

........................................................

⑥ តើប្អូនហៅជនរងគ្រោះដែលតំណាងដោយមេធាវី និងផ្តល់សក្ខីកម្មនៅតុលាការដូចម្តេច?

........................................................

........................................................

**សាលក្រម/សាលដីកា៖** សេចក្តីសម្រេចជាលាយលក្ខណ៍អក្សររបស់តុលាការពន្យល់ថា បុគ្គលនោះមានទោស ឬគ្មានទោសក្នុងបទឧក្រិដ្ឋកម្ម ដោយយោងទៅលើភ័ស្តុតាង និងច្បាប់។

**ការដាក់ទោស៖** ការផ្តន្ទាទោសរបស់តុលាការសម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋ។ ចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរ ជនល្មើសត្រូវទទួលទោសក្នុងពន្ធនាគារអស់មួយជីវិត។

# កេរដំណែលនៃយុត្តិធម៌



## អ.វ.ត.ក. ជួយជនរងគ្រោះកម្ពុជាក្នុងដំណើរការឆ្ពោះទៅរកសន្តិភាព និងការផ្សះផ្សា

### តើសំណងជាអ្វី?

សំណង គឺជាមធ្យោបាយផ្សេងៗក្នុងការទទួលស្គាល់នូវការឈឺចាប់ដែលជនរងគ្រោះនៃអំពើឧក្រិដ្ឋបានទទួល។ បន្ទាប់ពីការជំនុំជម្រះ អ.វ.ត.ក. បានទទួលស្គាល់**គម្រោងសំណងចំនួន ២៦!** នោះជាមធ្យោបាយមួយដើម្បីបង្ហាញថា ទុក្ខទោសដែលបង្កដោយខ្មែរក្រហមនឹងមិនអាចបំភ្លេចបាន។



**កម្រងពាក្យសូមអភ័យទោសជាសាធារណៈរបស់ឌុច**



**«ផ្កាស្លាក្រោមអង្គការ»**

របាំសហសម័យ និងពិព័រណ៍អំពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម។

**«ពេលវេលាដែលត្រូវចងចាំ»**

ការប្រឡងសរសេរទំនុកចម្រៀងដែលអាចឱ្យសិល្បករវ័យក្មេងផលិតតន្ត្រីចងចាំអំពីប្រវត្តិសាស្ត្រកម្ពុជា។





**អេប-កម្មវិធីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហម**

ព័ត៌មានប្រវត្តិសាស្ត្រដែលផ្សព្វផ្សាយនៅលើកម្មវិធីមួយ។



**គម្រោងផ្សះផ្សាផ្លូវចិត្តសម្រាប់អ្នកផ្តល់សក្ខីកម្ម**

ដើមបណ្តឹងរដ្ឋប្បវេណីមានការមើលថែពីអ្នកចិត្តសាស្ត្រ ដើម្បីជួយពួកគេប្រឈមមុខនឹងភាពឈឺចាប់ និងការបាត់បង់របស់ពួកគេ។



**គម្រោង «អណ្តើកក្លាហាន»**

ការសម្តែងល្ខោនដែលឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។

### ការចងចាំអំពីភ្នំពេញ

ស្វែងរកទីតាំងសំខាន់ៗនៅក្នុងរាជធានី ហើយភ្ជាប់ខ្លួនទៅនឹងអតីតកាលដើម្បីចងចាំ បង្ហាញការគោរព និងរៀនសូត្រ។

- **ទួលស្លែង៖** បូជនីយដ្ឋាននៃការចងចាំនៃមន្ទីរសន្តិសុខ ស-២១ ដែលគេប្រើជាគុកឃុំឃាំង។
- **មជ្ឈមណ្ឌលធនធាន អ.វ.ត.ក.៖** បណ្ណុំធនធាន ដើម្បីសិក្សាបន្ថែមអំពីដំណើរការកាត់ក្តី និងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម
- **ជើងឯក៖** ជាទីតាំងមួយដែលខ្មែរក្រហមបានសម្លាប់មនុស្សជាច្រើននាក់។




**ជនរងគ្រោះ៖** ជាមនុស្សដែលរងការឈឺចាប់ផ្លូវកាយ ផ្លូវចិត្ត ដោយសារឧក្រិដ្ឋកម្មបង្កឡើងដោយខ្មែរក្រហម។

**ច្បាប់៖** សំណុំនៃវិន័យដែលគ្រប់គ្នាអនុវត្ត ដើម្បីធានានូវសុវត្ថិភាព និងសន្តិភាពសង្គម។



# សម្រាប់មនុស្សជំនាន់ក្រោយ



**និមិត្តសញ្ញា អ.វ.ត.ក.** មានរូបតំណាងយុត្តិធម៌ពីសម័យបុរាណអមដោយក្ចួរផ្លែអូលីវ ដែលជានិមិត្តសញ្ញាតំណាងសន្តិភាពរបស់អង្គការសហប្រជាជាតិ។

### បន្ទាប់ពីជំនុំជម្រះ

បន្ទាប់ពីការជំនុំជម្រះក្តីបានបញ្ចប់នៅក្នុងឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ បានព្រមព្រៀងបន្តធ្វើការជាមួយគ្នា ដើម្បីរក្សាកេរដំណែលនៃការកាត់ក្តី។ បេសកកម្មរបស់ អ.វ.ត.ក. បានប្រែក្លាយមកជាការចែករំលែកព័ត៌មានជាមួយមនុស្សគ្រប់រូប ដូចជាតាមរយៈសៀវភៅមគ្គុទេសក៍នេះជាដើម។

*អ្នកដែលមិនចងចាំអតីតកាល ងាយនឹងដើរជាន់ដានសាជាថ្មី*
*- លោក ចច សាន់តាយ៉ាណា*



### ហេតុអ្វីការរៀនពីប្រវត្តិសាស្ត្រមានសារៈសំខាន់?

ការរៀនពីប្រវត្តិសាស្ត្រជួយយើងក្នុងការទប់ស្កាត់ព្រឹត្តិការណ៍អាក្រក់នានាដូចជាសម័យខ្មែរក្រហម កុំឱ្យកើតឡើងម្តងទៀត។ ការអប់រំជួយឱ្យយើង និងមនុស្សជំនាន់ក្រោយ ចងចាំពីព្រឹត្តិការណ៍អស់ទាំងនោះ។

### ហេតុអ្វីយុត្តិធម៌មានសារៈសំខាន់?

យុត្តិធម៌អនុញ្ញាតឱ្យមនុស្សបើកចិត្តចែករំលែករឿងរ៉ាវបញ្ជាក់ពីអ្វីដែលបានកើតឡើងក្នុងរបបខ្មែរក្រហម និងរក្សារឿងរ៉ាវទាំងនោះ សម្រាប់អ្នកជំនាន់ក្រោយតាមរយៈខ្សែវីដេអូ និងកំណត់ត្រា។

យុត្តិធម៌ធានាថា អ្នកទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម ត្រូវទទួលទោស។ នេះនាំមកនូវការបិទបញ្ចប់សំណុំរឿងសម្រាប់សង្គម និងអាចឱ្យយើងបន្តទៅមុខ ទៅកាន់សន្តិភាពនាអនាគត!

### ចំពោះឪពុកម្តាយ ឬលោកតាលោកយាយ ការរៀបរាប់រឿងពីអតីតកាល មិនមែនជារឿងងាយស្រួលទេ ព្រោះ...



ពួកគាត់ប្រហែលជាខ្មាសអៀន និងមិនចង់ឱ្យប្អូនក្រៀមក្រំចិត្ត។



ជាញឹកញយ វាឈឺចាប់ពេលនិយាយបទពិសោធន៍លំបាកៗពីអតីតកាល ហើយវាអាចធ្វើឱ្យរបួសផ្លូវចិត្តឡើងវិញ។

### ប្អូនអាចសួរសំណួរទៅកាន់ឪពុកម្តាយ និងតាយាយរបស់ប្អូន ពីព្រោះ...



វាជារឿងមានប្រយោជន៍ ក្នុងការរៀនពីបទពិសោធន៍ពីអតីតកាល។



វាជាផ្នែកដ៏សំខាន់នៃប្រវត្តិសាស្ត្រកម្ពុជា។

**សំណួរ៖**

៧ តើគម្រោងសំណងប៉ុន្មានត្រូវបានទទួលស្គាល់?

..........................................................

៨ តើរូបសញ្ញានៃសន្តិភាពក្នុងនិមិត្តសញ្ញារបស់ អ.វ.ត.ក. ប្រើមែកផ្លែអ្វី?

..........................................................

..........................................................

៩ តើការនិយាយរៀបរាប់អំពីអតីតកាលមានប្រយោជន៍អ្វីខ្លះ?

..........................................................

..........................................................

..........................................................

**កេរដំណែល៖** ផលយូរអង្វែងនៃការកាត់ក្តីរបស់ អ.វ.ត.ក. រួមមានយុត្តិធម៌ និងការរៀនសូត្រពីអតីតកាល។

**របួសផ្លូវចិត្ត ៖** ការឈឺចាប់ដែលកប់ជ្រៅក្នុងចិត្ត និងការឈឺចាប់ដែលបណ្តាលពីបទពិសោធន៍ដ៏លំបាក។